ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ០១

ចុះថ្ងៃទី១០-០១-០១

សាលដីកា

លេខ: ៥៤

ចុះថ្ងៃទី២៦-០៩-០១

តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ខែកញ្ញាឆ្នាំ២០០១

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក ជីវ កេង ចៅក្រម

៤ - លោក សោម សិរីវឌ្ឍ ចៅក្រម

៥ - លោក យស់ សុខឿន ចៅក្រមរបាយការណ៍

លោក យាង ស្រ៊ិន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ប៉ែន សាវឿន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ៩៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០០០ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០៣ ចុះថ្ងៃទី២៨ ខែ សីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ក្រុងសេចក្តីសំរេច ដោយយកពីសាលាឧទ្ធរណ៍យកមូលហេតុប្រភេទវត្ថុតាងវីបអូបពុំគ្រប់គ្រាន់ បញ្ជាក់ឯនូវសកម្មភាពនេសាទជាក់ស្តែងខុសច្បាប់ ដែលផ្ទុយពីសកម្មភាពនេសាទនៅក្នុងដែនពាមឃ្លាត់មួយអចិន្ត្រៃយ៍ ដោយមានផ្ទុកនិងឧបករណ៍នេសាទសំរាប់ធ្វើការនេសាទគ្រប់កាលៈទេសៈបាន និងបណ្តឹងសាទុក្ខលេខ ៨២ ចុះថ្ងៃទី ០៦-៩-២០០០ របស់លោកអ៊ិន អយ តំណាងអោយជលផល តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០៣ ចុះថ្ងៃទី១៨-០៨-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូលនិងសំណុំរឿងព្រហ្មទណ្ឌលេខ០១ចុះថ្ងៃទី១០-០១-០១ របស់តុលាការកំពូល។

- ជនជាប់ចោទឈ្មោះ ម៉េង ធីដៀប "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៣៦ ឆ្នាំ ជាតិ វៀតណាម មុខរបរនេសាទត្រី ទីលំនៅសព្វថ្ងៃភូមិទី៥ ឃុំ កំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ លំ អេង ម្តាយឈ្មោះលូ ណែ ប្តីឈ្មោះអេង ឆាយលី ។ នៅក្រៅឃុំ ទោសពីមុន គ្មាន ។

- ត្រូវចោទពីបទៈ រំលោភដែននេសាទខុសច្បាប់លើដែនបំរុងទុក ប្រព្រឹត្តនៅ

ចំណុចផ្លូវទឹក ឃុំ មេទឹក ស្រុកបាកាន ខេត្ត ពោធិសាត់ កាលពីថ្ងៃទី០៤-០៣-៩៩ បទល្មើស ដែលមានចែង តាមបញ្ញត្តិមាត្រា៣៥ ៣៦ ៣៨ និង៣៩ នៃក្រឹត្យ-ច្បាប់លេខ៣៣ ក្រ.ច ។

- មេធាវី លោក សែម ចិន្តា

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ "ម្ចាស់បណ្តឹងសាទុក្ខ" លេខ៩៣ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០០ ។

- ដើមបណ្តឹងរដ្ឋប្បវេណីលោក លី គឹមហាន ប្រធាននាយកដ្ឋានជលផលនៃក្រសួងកសិកម្ម "ប្តឹងសាទុក្ខ" តំណាងដោយលោក អ៊ុន អយ ។

- មេធាវី លោក ឡាយ សំណាង .

- តាមពាក្យបណ្តឹងចុះថ្ងៃទី១៣-៥-៩៩ របស់លោកលី គឹមហាន ប្រធាននាយកដ្ឋានជលផលនៃក្រសួងកសិកម្មថា: កាលពីថ្ងៃទី០៤-០៣-៩៩ វេលាម៉ោង១០កន្លះព្រឹក ក្រុមចំរុះជលផល បានដឹកនាំដោយតំណាងនាយកដ្ឋានជលផល បានចុះបង្ក្រាបបទល្មើសនេសាទតំបន់ដីរនាតកន្លែងនេសាទបំរុងទុក ដែលរដ្ឋហាមឃាត់នៅបឹងទន្លេសាប ឈ្មោះអេង ឆាយលី និងប្រពន្ធឈ្មោះម៉េវ ធីដៀប កំពុងនេសាទនៅចំណុចវ៉ាងដែននេសាទបំរុងទុក ដែលរដ្ឋហាមឃាត់ ពេលនោះសមត្ថកិច្ចជលផលចូលពិនិត្យ ត្រូវជនល្មើសនិងបក្សពួករត់គេចខ្លួនអស់នៅតែនារី ម៉េវ ធីដៀប ជាប្រពន្ធជនល្មើស សមត្ថកិច្ចបានដកហូតវត្ថុតាងមាន ទូកម៉ាស៊ីនម៉ាកមីស៊ូប៊ីស៊ីមួយគ្រឿង ផ្ទះដែផទំហំ "២០ម.៧ម "មួយខ្នង អួនសៃ្បមុងមួយវង់ ម៉ាស៊ីនភ្លើងម៉ាកអែហ្វ៦ ចំនួនមួយគ្រឿងនិង ធុងក្លាសេ្សចំនួនពីរធុង ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តពោធិសាត់ ថា:សុំរេចចោទប្រកាន់លើឈ្មោះម៉េវ ធីដៀប ភេទស្រី អាយុ ៣៦ ឆ្នាំ ពីបទនេសាទខុសច្បាប់ក្នុងដែននេសាទសាធារណៈនិងកន្លែងនេសាទបំរុងទុក ប្រព្រឹត្តនៅចំណុចផ្លូវទឹក ឃុំមេផ្ទុះ ស្រុកបាកាន ខេត្ត ពោធិសាត់ កាលពីថ្ងៃទី០៤-៣-៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥ ៣៦ ៣៨ ៣៩ នៃក្រឹត្យច្បាប់លេខ៣៣ក្រ.ច ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៩ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ របស់តុលាការខេត្ត ពោធិសាត់ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- អោយរួចផុតពីបទចោទលើឈ្មោះម៉េវ ធីដៀប អាយុ ៣៦ ឆ្នាំ ភេទស្រី ពីបទ:នេសាទខុសច្បាប់ក្នុងដែនបំរុងទុកដីរនាត ដែលត្រូវហាមឃាត់ និងវ៉ាងដែននេសាទសាធារណៈ ស្ថិតនៅក្នុងឃុំ មេទឹក ស្រុកបាកាន ខេត្តពោធិសាត់ ។ មានទីលំនៅបច្ចុប្បន្នភូមិទី៥ ឃុំ កំពង់លួង ស្រុក ក្រគរ ខេត្ត ពោធិសាត់ របស់លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ពោធិសាត់ ។

២- បង្គាប់អោយនាយកដ្ឋានជលផល ប្រគល់សម្ភារៈដែលដកហូតរួមមាន: ១-ផ្ទះដែន០១ខ្នង ទំហំ ២០ម.៧ម ២-ម៉ាស៊ីនភ្លើងម៉ាកអែហ្វ០៦ ១គ្រឿង ៣-ធុងក្លាសេ្ស ចំនួន២ ៤- ទូកម៉ាស៊ីនម៉ាកមីស៊ូប៊ីស៊ី ដេ២០ "ឈ្មោះទាន់សម័យ "ចំនួន០១គ្រឿង អោយទៅ

ឈ្មោះ ម៉េង ធីដៀប និងប្តីឈ្មោះ អេង ឆាយលី វិញគ្រប់ចំនួនដូចខាងលើ ។ ក្នុងករណីមានការបាត់បង់ឬខូចខាត ក្នុងការគ្រប់គ្រងពីភាគីណា ទទួលខុសត្រូវទុកថែរក្សា ដោយធ្វេសប្រហែសត្រូវទទួលខុសត្រូវតាមច្បាប់ ព្រហ្មទណ្ឌអន្តរកាលដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៥៧ ។ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខតំណាងនាយកដ្ឋានជលផលនិង ឈ្មោះ អេង ឆាយលី ជាប្តី ជាអ្នកទទួលការផ្ទេរសិទ្ធិ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ តាមបណ្តឹងចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ របស់លោក អ៊ុន អយ តំណាងប្រធាននាយកដ្ឋានជលផលនៃក្រសួងកសិកម្ម ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ២៩ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ របស់តុលាការខេត្ត ពោធិសាត់ លើសេចក្តីសំរេចទាំងមូល។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: រឿងដែលកើតឡើងចោទពីបទ: ទាំងដែននេសាទ ការចុះចាប់មិនមែនជាបទល្មើសជាក់ស្តែងទេ ម៉េង ធីដៀប គ្មានលិខិតអនុញ្ញាតពិសេសនេសាទត្រី សូមឲ្យក្រុមប្រឹក្សាសំរេចតាមច្បាប់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២០៣ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០-១២-៩៩ របស់ឈ្មោះអ៊ុន អយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៩ចុះថ្ងៃទី១២-១១-៩៩ របស់តុលាការខេត្ត ពោធិសាត់ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះ អេង ឆាយលី និងឈ្មោះ អ៊ុន អយ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខតាមបណ្តឹងលេខ ៨២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០០០ របស់លោកអ៊ុន អយ តំណាងអោយប្រធាននាយកដ្ឋានជលផលនៃក្រសួងកសិកម្ម ប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២០៣ ចុះថ្ងៃទី១៨-០៨-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញបណ្តឹងសាទុក្ខតាមបណ្តឹងលេខ ៩៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០០ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០៣ ចុះថ្ងៃទី១៨-៨-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេច ដោយដកពីសាលាឧទ្ធរណ៍យកមូលហេតុប្រភេទវត្ថុតាងទីបអូរ ពុំឆ្លុះបញ្ចាំង នូវសកម្មភាពនេសាទជាក់ស្តែងខុសច្បាប់ ដែលផ្ទុយពីសភាពនេសាទដែលហាមឃាត់ មួយផងជាអចិន្ត្រៃយ៍ ដោយមានផ្ទុកនិងឧបករណ៍នេសាទសំរាប់ធ្វើការនេសាទគ្រប់កាលៈទេសៈ។

- បានឃើញសារណាចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០០១ របស់នាយកដ្ឋានជលផលនៃក្រសួងកសិកម្ម ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានឃើញសារណាតបចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះ ម៉េង ធីដៀប ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ បណ្ដឹងសាទុក្ខរបស់លោកអ៊ិន អយ និងបណ្ដឹងសាទុក្ខរបស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

- មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ ម៉េង ធីដៀប ពីបទ៖ វាំងដែននេសាទខុសច្បាប់ និងនេសាទខុសច្បាប់លើដែនបំរុងទុក ប្រព្រឹត្តនៅខេត្តពោធិសាត់កាលពីថ្ងៃទី០៤-៣-៩៩ ដូច្នេះសូមបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ២០៣ចុះថ្ងៃទី១៨-៨-២០០០ របស់សាលាឧទ្ធរណ៍ ។

- បានស្ដាប់ក្រឡាបញ្ជីអានសារណាក្នុងបណ្ដឹងសាទុក្ខ របស់ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៥-១២-២០០០ ។

- បានស្ដាប់លោកអ៊ិន អយ តំណាងឱ្យជលផល បានលើកឡើងនាពេលសវនាការថា៖ ក្រុមចំរុះបានចុះប្រតិបត្តិការអំពីការហាមឃាត់ដែននេសាទ ដែលបានប្រកាសជូនដំណឹងហើយនោះ ឃើញការប្រព្រឹត្តបទល្មើសខុសច្បាប់ក្នុងដែននេសាទរបស់ឈ្មោះ ម៉េង ធីដៀប ។ ក្រុមចំរុះបានរឹបអូសសម្ភារៈខុសច្បាប់ហើយដែរ ដូច្នេះសូមតុលាការកំពូលមេត្ដារកយុត្ដិធម៌តាមច្បាប់ ។

- បានស្ដាប់ក្រឡាបញ្ជីអានសារណាតបរបស់ឈ្មោះ ម៉េង ធីដៀបចុះថ្ងៃទី១៦-២-០១ .

- បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់លោក ទូយ សំណាង ការពារអោយជលផល បានលើកឡើងនាពេលសវនាការថា៖ ក្នុងនាមខ្លួនជាអ្នកការពារអោយនាយកដ្ឋានជលផល ក្រោយពីបានស្ដាប់អង្គសវនាការនិងសារណាតបមកឃើញថា ជនល្មើសឈ្មោះ ម៉េង ធីដៀប ប្ដីឈ្មោះ អេង នាឃី ជាជនជាតិវៀតណាម បានប្រព្រឹត្តបទល្មើសក្នុងដែននេសាទដែលជាកន្លែងនេសាទបំរុងទុក ហើយរដ្ឋក៏បានហាមឃាត់នៅបឹងទន្លេសាបនោះហើយដែរ តែជនល្មើសឈ្មោះនេះ នៅតែអនុវត្តនេសាទខុសច្បាប់ជានិច្ច ពេលនោះសមត្ថកិច្ចជលផល ចុះត្រួតពិនិត្យនិងចុះដេញចាប់ ស្រាប់តែបក្សពួករត់គេចខ្លួន ទើបរឹបអូសបានសម្ភារៈឧបករណ៍របស់ឈ្មោះ ម៉េង ធីដៀបអ្នកប្រព្រឹត្ត ។ បើពិនិត្យទៅលើកំណត់ហេតុមានគ្រប់គ្រាន់ទៅលើជនល្មើសដែលទទួលស្គាល់សម្ភារៈឧបករណ៍ ក្នុងការប្រព្រឹត្តបទល្មើសនេសាទ ម្យ៉ាងទៀតតាមច្បាប់របស់ជលផល បានបែងចែកតំបន់នេសាទមានចំនួនពកន្លែង ជាប្រភេទធុរស្របអប់ហើយរដ្ឋក៏បានចេញបទបញ្ជាមានរយៈពេលច្រើនខែដែរ មុននឹងចុះត្រួតពិនិត្យលើដែននេសាទហាមឃាត់ ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់លោកស៊ែម ចិន្ដា ការពារអោយជនជាប់ចោទបានលើកឡើងនាពេលសវនាការថា៖ ការលើកឡើងរបស់មេធាវីការពារឱ្យជលផលនោះ គឺគ្រាន់តែជាការបន្ទុកទៅលើកូនក្ដីខ្លួនប៉ុណ្ណោះ បើនិយាយទៅលើកូនក្ដីខ្លួនក្នុងតួនាទីជាកម្មករនេសាទរបស់យោធា រកផលត្រីឱ្យកងទ័ពប៉ុណ្ណោះ ការដែលកូនក្ដីខ្លួននេសាទនោះ គឺនៅក្នុងតំបន់ឡូត៍នេសាទរបស់យោធាដែរ ការដែលក្រុមចំរុះធ្វើកំណត់ហេតុក៏ពុំបានសមស្របទៀយ ព្រោះថា ត្រូវមានគណៈកម្មការនិងរដ្ឋអំណាចមូលដ្ឋានចូលរួមទើបត្រឹមត្រូវ ការដែលមានបទបញ្ជាពីការហាមឃាត់របស់រដ្ឋក៏កូនក្ដីខ្លួនមិនបានដឹងផង ដូចនេះកូនក្ដីខ្លួនពុំបាន

ប្រព្រឹត្តល្មើសនេសាទទេ ហើយផ្ទះ ផែនិងសំភារៈសំចតក្រៅតំបន់ហាមឃាត់នៅជាប់នាមួយ
ប្រជាជនច្រើនទៀត ។ នេះ ហើយបានជាតុលាការខេត្ត និងសាលាឧទ្ធរណ៍សំរេចអោយ
អ្នកស្រី ម៉េង ធីដៀប រួចផុតពីការចោទនឹងប្រគល់ផ្ទះក្បូនសំភារៈមកឱ្យលោកអេង ឆាយលី
គឺជាការត្រឹមត្រូវតាមទំនងនិងគតិច្បាប់ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាល
ដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍តាមច្បាប់ ។

- បានស្តាប់សេចក្តីសន្និដ្ឋាននាពេលសវនាការរបស់តំណាងមហាអយ្យការ អម
តុលាការកំពូលថា ពុំមានអ្វីក្នុងការបន្ថែមទៀតទេ សូមរក្សាសន្និដ្ឋានរបស់ខ្លួនដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ.

- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទនិងអគ្គព្រះរាជអាជ្ញា អម
សាលាឧទ្ធរណ៍ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ជន
ជាប់ចោទ និង មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ០៨៣ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០០ របស់ អគ្គ
ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងបណ្តឹងសាទុក្ខលេខ៨៦ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០០០របស់
លោកអ៊ុន អយ តំណាងឱ្យនាយកដ្ឋានជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ធ្វើឡើង
ក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកឡើងមកជំនុំជំរះតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់
តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមសំរេចឱ្យជនជាប់ចោទរួចផុត
ពីបទល្មើសនេសាទខុសច្បាប់ក្នុងដែនបំរុងទុក ដីរនាតដែលត្រូវហាមឃាត់និងទាំងដែននេសាទ
សាធារណៈស្ថិតនៅក្នុងឃុំ មេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់ និងឱ្យនាយកដ្ឋានជលផលប្រគល់
សម្ភារៈដែលដកហូត កាលពីថ្ងៃទី៤ ខែមិនា ឆ្នាំ១៩៩៩ អោយទៅឈ្មោះម៉េង ធីដៀប វិញ
នោះ ជាការភន្តច្រឡំពីព្រោះថា ការអះអាងរបស់ក្រុមចំរុះថាឈ្មោះអេង ឆេលី ប្រពន្ធ
ឈ្មោះម៉េង ធីដៀបនិងបក្សពួក បានប្រព្រឹត្តល្មើសដោយខ្ទាំងដែននេសាទដែលត្រូវការពារ
និងកន្លែងនេសាទបំរុងទុកដីរនាតនៅចំណុចផ្លូវទឹក កន្លែងនេសាទបំរុងទុកគឺជនល្មើសទាំងនេះ
បាននេសាទខុសច្បាប់ជាអចិន្ត្រៃយ៍ ។

- យល់ឃើញថា គណៈកម្មការចំរុះបានឃាត់ផ្ទះនិងសម្ភារៈទាំងនេះ ក្នុងវង្វង់ដែន
នេសាទដែលត្រូវហាមឃាត់ ហើយជនល្មើសឈ្មោះម៉េង ធីដៀបបានទទួលសារភាព ក្នុងកំណត់ហេតុ
ចុះថ្ងៃទី០៤-៣-៩៩ ថាខ្លួនពិតជាបានប្រព្រឹត្តបទល្មើសនេះប្រាកដមែន ។ ដូច្នេះជនជាប់ចោទ
ពុំមានភស្តុតាងដោះបន្ទុកបានឡើយ ។

- យល់ឃើញថា ផ្ទះដែលរឹបអូសក៏ជាវត្ថុតាងមួយសំរាប់ផ្ទុកឧបករណ៍និងសំរាប់ធ្វើ

ជាទីតាំងប្រព្រឹត្តបទល្មើសជាអចិន្ត្រៃយ៍រួចមកហើយ ហើយដែលគ្មានមូលហេតុផ្សេងណាមួយដែលតម្រូវអោយជនជាប់ចោទទៅព្រះទីតាំងនៅទីនោះទេ ។

- យល់ឃើញថា ការដែលលោកមេធាវីជនជាប់ចោទ លើករឿងនាពេលសវនាការនេះថាកំណត់បទល្មើស ចុះថ្ងៃទី០៤-៣-៩៩ ពុំមានសុពលភាពយកជាការបានទេ ដោយហេតុថា ពុំមានចុះពីមុខងាររបស់អ្នកចូលរួមនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះបញ្ហាសំខាន់គឺជនជាប់ចោទបានផ្តិតមេដៃទទួលស្គាល់អំពើល្មើសរបស់ខ្លួនរួចហើយ ។

- យល់ឃើញថា ជនជាប់ចោទបានផ្ញើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២០៣ចុះថ្ងៃទី១៨ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងនាយកដ្ឋានដលផល កំបាំងមុខជនជាប់ចោទម៉េង ធីដៀប ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្តឹងសាទុក្ខលេខ៩៣ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០០ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍និងបណ្តឹងសាទុក្ខលេខ៨២ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០០របស់លោកអ៊ិន អយ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២០៣ចុះថ្ងៃទី១៨ខែសីហា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ០១ចុះថ្ងៃទី១០ខែមករា ឆ្នាំ២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីទៀងវិញ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១ ។